# មគ្គុទ្ទេសក៍ក្នុង
# ការទប់ស្កាត់ទំនាស់ប្រកប
# ដោយប្រសិទ្ធភាព

# A Guide to An Effective Conflict Prevention

មេត្តាធមិ-កម្មវិធីកែប្រែទំនាស់

អង្គការ **សីលការ**

**ខែ ធ្នូ ២០០៤**

**រៀបចំ និងចងក្រងដោយៈ**

លោក ដួង វីរ័ត្ន

លោកស្រី សាន់ ផានិត

លោក សាក់ សុធា

**គូររូបភាពដោយ**

លោក ឡុង សុវណ្ណា

**បោះពុម្ពនៅរោងពុម្ព** គីម ឡុង

បោះពុម្ពលើកទី ១ ចំនួន ៥០០០ ក្បាល

**ឧបត្ថម្ភថវិការដោយៈ**

សេវាកម្មអភិវឌ្ឍន៍ប្រទេសអាល្លឺមង់

ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសកាណាដា

Supported by: **ded and CIDA**

**អង្គការ សិលការ**

ផ្ទះលេខ ៦ អេស ផ្លូវ លេខ ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ

Tel: (855) 23 217 872/210 902

Fax: (855) 23 213 108

Email: silaka@silaka.org

Website: www.silaka.org

# មគ្គុទ្ទេសក៍ក្នុងការទប់ស្កាត់ ទំនាស់ប្រកបដោយប្រសិទ្ធភាព

# A Guide to An Effective Conflict Prevention


ចងក្រងដោយៈ

មេត្តាធម៌-កម្មវិធីកែប្រែទំនាស់

អង្គការ **សីលការ**

Metathor-Conflict Transformation Programme

**SILAKA**



**December, 2004**

# មាតិការឿង


| | ទំព័រ |
|---|---|
| **មាតិការឿង** | **១** |
| **បុព្វកថា** | **២** |
| **១. ការស្វែងយល់ពីទំនាស់** | **៤** |
| ១.១ ការយល់ឃើញ | ៦ |
| ១.២ ការរើសអើង | ៨ |
| ១.៣ អត្តសញ្ញាណ | ១០ |
| ១.៤ ការស្មានទុក | ១២ |
| ១.៥ លោភៈ ទោសៈ មោហៈ | ១៣ |
| **២. យុទ្ធសាស្ត្រក្នុងការដោះស្រាយទំនាស់** | **១៥** |
| ២.១ ចរិតបុគ្គលក្នុងទំនាស់ | ១៥ |
| ២.២ ជំហរផលប្រយោជន៍ និង សេចក្តីត្រូវការ | ១៦ |
| ២.៣ ទំនាក់ទំនង | ២១ |
| ២.៤ ការផ្តល់ព័តិមានកែលំអ | ២៣ |
| ២.៥ ការវិភាគទំនាស់ | ២៤ |
| ២.៦ វិធីសាស្ត្រដោះស្រាយទំនាស់ | ២៧ |
| ២.៧ ដំណើរការដោះស្រាយបញ្ហា | ២៩ |
| ២.៨ ដំណើរការដោះស្រាយទំនាស់ | ៣២ |
| ២.៩ កម្មវិធីរបស់អង្គការសីលការ | ៣៤ |

# បុព្វកថា

ក្នុងសង្គមរស់នៅទាមទារត្រូវតែឱ្យមានភាពសុខដុមរមនា ហើយមានភាពសុខដុមរមនា ទើបកាត់បន្ថយ បាននូវភាពក្រីក្រ ។ ក្នុងការរស់នៅ តើមានសង្គមណា ប្រទេសណា ក្រុមណា គ្រួសារណា ឬអ្នកណា ជៀសផុត ពីទំនាស់បានឬទេ? -យើងមានឆន្ទៈនឹងឆ្លើយថា គ្មានថាមិនមានទំនាស់សោះនោះទេ ប៉ុន្តែសំខាន់គឺថាតើ **មាន ការដោះស្រាយទំនាស់** នោះឬទេ? ឬក៏ថា **ការដោះស្រាយនោះមានប្រសិទ្ធភាព** ឬទេ?

ការដោះស្រាយទំនាស់មានប្រសិទ្ធភាពទៅបាន តើគួរមានអ្វីខ្លះជាកត្តាសំខាន់ ? យើងគិតថា ការ ដោះស្រាយទំនាស់ ថ្វីត្បិតតែជាការងារសំរាប់សង្គមមនុស្សតាំងពីយូរយារណាស់មកហើយ ក្នុងនោះយើងពិនិត្យឃើញថា វិធីសាស្ត្រមានប្លែក១គ្នា ហើយនៅមិនទាន់មានក្បួនខ្នាតជាក់លាក់នៅឡើយ ។ ការងារដោះស្រាយទំនាស់នៅមូលដ្ឋានភាគច្រើនធ្វើទៅតាមសភាពជាក់ស្តែង ជាពិសេសផ្អែកលើការសំរុះសំរួលការផ្សះផ្សា ដោយមិនបានយកចិត្តទុកដាក់ចំពោះការស្វែងយល់ឱ្យ បាន ស៊ីជំរៅពី មូលហេតុឬអ្នកពាក់ព័ន្ធនឹង ទំនាស់នោះ ឬក៏ថាបានធ្វើដែរ តែមិនទាន់មានបែបបទការងារបានត្រឹមត្រូវ ។ កម្ពុជាដែលទើបនឹងមានពន្លកប្រជាធិបតេយ្យការងារដោះស្រាយទំនាស់ជាជំនាញថ្មី ដែលសកម្មភាព មានស្របគ្នានឹងការអនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។ការដោះស្រាយទំនាស់មានប្រសិទ្ធភាព លុះត្រាណាតែ គូភាគីនៃទំនាស់ទាំងឡាយមានការឯកភាពទទួលយកការដោះស្រាយនោះ ដោយមិនមានការបង្ខិតបង្ខំពីអ្នក ណាម្នាក់ឡើយ ដែលក្នុងភាសា ឬពាក្យពេចន៏ នៃការដោះស្រាយទំនាស់និយាយ ថា " **ការដោះស្រាយតាមវិធីសាស្ត្រឈ្នះ-ឈ្នះ** " ចង់បានការដោះស្រាយមានប្រសិទ្ធភាពជាការពិត វាទាមទារនូវក្បួនខ្នាតមួយជាក់លាក់ ។សិលការដែលជាអង្គការមានកម្មវិធីបណ្តុះបណ្តាល ក៏មានផ្នែកបណ្តុះបណ្តាល ការដោះស្រាយទំនាស់នេះផងដែរ ។ វាជាការរៀនសូត្រពីការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការដែលមានន័យថា ឱ្យប្រជាពលរដ្ឋរៀន សូត្រអំពីជំនាញថ្មីនេះហើយរៀបចំជាក្រុមធ្វើការដោះស្រាយបញ្ហានៅក្នុងភូមិ-ឃុំជូនប្រជាពលរដ្ឋ ដោយមិនគិតពីផលកំរៃអ្វីទាំងអស់ ។ សៀវភៅដែលមានឈ្មោះថា " មគ្គុទេសក៏ក្នុងការទប់ស្កាត់ទំនាស់ប្រកបដោយ ប្រសិទ្ធភាព "

នេះកើតចេញពីការចងក្រងដោយគួបផ្សំគំនិតទាំងឡាយពីប្រទេសនានា និងបទពិសោធន៍ដែលយើងទទួលបានពី ការបណ្តុះបណ្តាល នៅតាម វគ្គក្នុងខេត្តស្វាយរៀង និងខេត្តកំពង់ធំ ពីឆ្នាំ ២០០៣ មក ២០០៤ កន្លងមកនេះ ។ សៀវភៅនេះ ជាសមិទ្ធផលមួយរបស់យើងជា សង្គមស៊ីវិល សំរាប់ការជួយក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ដែលយើងមានជំនឿជឿជាក់ថា តាមរយៈ ការជ្រួតជ្រាបអំពីគំនិត ក្នុងសៀវភៅនេះវានឹងនាំមកនូវឥទ្ធិពលមួយផ្នែកធំ ក្នុងការកាត់បន្ថយនូវភាពក្រីក្រ របស់ប្រជាពលរដ្ឋកម្ពុជា។យើងសូមទទួលនូវគំនិត យោបល់ ទិតៀនស្ថាបនាទាំងឡាយពីលោក-អ្នកដើម្បីកែលំអស្នាដៃនេះ និងសូមឧទ្ទិសជូនពរដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបឱ្យទទួលបាននូវវឌ្ឍនភាពដោយបានជៀសផុតជាអតិបរិមា ពីវិបត្តិនៃទំនាស់ទាំងឡាយ ដែលជាចំណុចអវិជ្ជមានរារាំងក្នុងជីវិតរបស់ខ្លួន ។

**នាយិកាប្រតិបត្តិអង្គការសីលការ**

**ធីដា ឃិះ**

# ការស្វែងយល់ពីទំនាស់

## អ្វីទៅហៅថាទំនាស់ ?



ទំនាស់កើតឡើងដោយសារមនុស្សពីរនាក់ ឬក្រុមពីរដែលមិនយល់ព្រមស្របគ្នា

ឬមិនចុះសំរុងគ្នា ឬប្រកាន់បក្សពួកគ្នា ឬប្រកួតប្រជែងគ្នា ។

**រាល់ទំនាស់តែងមានគន្លឹះសំរាប់ដោះស្រាយ**

# តើទំនាស់កើតឡើងដោយសារមូលហេតុអ្វី ?






# ការយល់ឃើញ

**តើអ្វីទៅហៅថា ការយល់ឃើញ ?** គឺជា ការកំណត់នូវអ្វីមួយតាមរយៈការមើលឃើញ ឬស្តាប់ឮ ។

ជាងឈើមើលឃើញដុំឈើ-
ថាមានប្រយោជន៍សំរាប់ធ្វើរទេះ







គ្រូផ្សំថ្នាំខ្មែរពេលមើលឃើញដុំឈើ នោះនឹកគិតថាដុំឈើនោះមានសារប្រយោជន៍ សំរាប់ផ្សំធ្វើថ្នាំព្យាបាលជំងឺផ្សេងៗ ។



ស្ត្រីជាមេផ្ទះមើលឃើញដុំឈើ
មានប្រយោជន៍ សំរាប់ធ្វើអុស ដាំបាយនិងដុតចំអិនម្ហូបអាហារ ។

# តើការយល់ឃើញរបស់មនុស្សម្នាក់ៗដូចគ្នា រឺទេ?

ការយល់ឃើញរបស់មនុស្សម្នាក់ៗមានលក្ខណះខុសៗគ្នា ។ ការមើលឃើញវត្ថុមួយហើយយល់ខុសៗគ្នាមក ពីតំរងរបស់យើងម្នាក់ៗមានលក្ខណះខុសៗគ្នា ។ ការយល់ឃើញខុសៗគ្នា នេះគឺនាំទៅ រកការខ្វែងគំនិត និងជំលោះ ។







## វិធីសាស្ត្រ ទប់ស្កាត់កុំអោយមានទំនាស់ :

- ត្រូវចេះសាកសួរគ្នា
- ត្រូវចេះអោយតំលៃការយល់ឃើញរបស់ខ្លួន និងអ្នកដទៃ
- ត្រូវទទួលស្គាល់ថាមនុស្សអាចទស្សនះខុសពីយើង មិនមែនគេខុសទេ
- ត្រូវចេះយោគយល់ និងអធ្យាស្រ័យ

# ការរើសអើង



- **តើការរើសអើងបណ្តាលអោយមានទំនាស់ទេ ?**

ការរើសអើងរឺការប្រកាន់ជាតិសាស្ត្រ ពណ៌សំបុរ យេនឌ័រ ឋានៈ តួនាទី គឺជាប្រភពដែលនាំអោយមានទំនាស់យ៉ាងស្រួចស្រាវ ។

**តើធ្វើដូចម្តេចដើម្បីកុំអោយមានទំនាស់ដោយសារការរើសអើង ?**



# ដើម្បីកុំអោយមានទំនាស់ដោយសារតែការរើសអើងនេះ

យើងត្រូវ:

- យើងគ្រប់រូបគួរតែបង្កើតបរិយាកាសយល់ចិត្តគ្នា
- ធ្វើការរួមគ្នារវាងក្រុម
- យល់ដឹងពីច្បាប់ ការគោរពសិទ្ធិ
- ត្រូវចេះអត់ធ្មត់ ចេះស្តាប់ និងការចូលរួមពិភាក្សាគ
- លើកទឹកចិត្តអោយមានការចូលរួម និងស្រឡាញ់រាប់អានគ្នា

**⊗ អ្នកមិនអាចកែប្រែ ឬផ្លាស់ប្តូរសង្គមបានឡើយ ប្រសិនបើអ្នកមិនកែប្រែ ឬផ្លាស់ប្តូរខ្លួនឯងជាមុនសិន ។**

**⊗ បញ្ឈប់អំពើរើសអើងក្នុងសង្គម នឹងនាំអោយយើងមានសន្តិភាព ។**

# អត្តសញ្ញាណ

## តើអ្វីជាអត្តសញ្ញាណ ?



អត្តសញ្ញាណ គឺជាសញ្ញាសំគាល់នូវអ្វីមួយដែលមនុស្សគ្រប់រូបប្រកាន់យក គោរពស្រឡាញ់ពេញចិត្ត និងការពារ ។




## តើមានរឿងអ្វីកើតឡើង ប្រសិនបើយើងមើលងាយអត្តញ្ញាណគ្នា ទៅវិញទៅមក ?




## តើយើងត្រូវធ្វើដូចម្តេចដើម្បីកុំឱ្យ មានទំនាស់ ដោយសារការមើលងាយអត្តសញ្ញាណ ?

⊗ កុំមើលងាយអត្តសញ្ញាណ

⊗ ចេះគោរព និងអោយតំលៃគ្នាទៅវិញទៅមក

# ការវាយស្មានទុក

ការវាយស្មានទុក គឺជាគំនិតដែលកើតឡើងដោយការវាយស្មានទុកជាមុនទៅលើរបស់អ្វីមួយ ឬក៏ក្រុមមួយ ដោយពុំមានន័យល្អ ឺរហេតុផលល្អ ត្រឹមត្រូវទេ ។ការវាយស្មានទុក ជាមុនមិនមែនកើតចេញពីអ្វី ដែលយើងបានឮ និងបានឃើញទេ ប៉ុន្តែផ្ទុយទៅវិញវាកើតឡើងពីការយល់ឃើញហើយនិយាយចេញមកតែម្តង ។ ដូច្នេះទំនាស់តែងតែ កើតឡើងពេល ដែលការវាយស្មានទុកដោយពុំសមហេតុផល ដែលខុសពី ការពិត-ទាំងស្រុង ។




## តើការវាយស្មានដោយគ្មានសួរមូលហេតុអាចនាំអោយមានផលអ្វីខ្លះ ?

- ⊗ អាចអោយមានកំហឹងដាក់គ្នា ទៅវិញទៅមក
- ⊗ អាចនាំអោយមានទំនាស់ជាមួយគ្នា

## តើយើងគួរធ្វើដូចម្តេចដើម្បីជៀសវាងទំនាសដោយសារការវាយស្មានទុកជាមុន ?

- ⊗ ចេះសួររកហេតុផល អោយបានច្បាស់
- ⊗ ចេះស្តាប់ និងផ្តល់ឱកាសអោយគេពន្យល់

# លោភៈ ទោសៈ មោហៈ

**លោភៈ** ( ភាពលោភលន់ )




**ទោសៈ (ការស្អប់ )**



**មោហៈ** ( សេចក្តីវង្វេង )



ទាំងអស់នេះជាប្រភពនៃទំនាស់

## ដើម្បីជៀសវាងទំនាស់កើតឡើងដោយសារ ទោសៈ មោហៈ លោភៈ យើងត្រូវ :

⊗ អោយតំលៃ គោរពស្តាប់គ្នាទៅវិញទៅមក

⊗ គិតពិចារណា ស្គាល់ហេតុផល ខុសត្រូវ

⊗ ពិភាក្សារគ្នារកដំណោះស្រាយរួម

⊗ យោគយល់អធ្យាស្រយ័គ្នា

# យុទ្ធសាស្ត្រក្នុងការដោះស្រាយទំនាស់

## ចរិតបុគ្គលក្នុងទំនាស់



# ជំហរ ផលប្រយោជន៍ និងសេចក្តីត្រូវការ




⇨ មនុស្សគ្រប់រូប ពេលមានទំនាស់តែងតែប្រកាន់យក **ជំហរ** ជានិច្ច។ តែការដោះស្រាយទំនាស់តំរូវអោយភាគីទំនាស់ គិតទៅលើ **តំរូវការ** និង **ផលប្រយោជន៍** ទើបអាចរកដំណោះស្រាយបាន ។

**ឧទាហរណ៍ :**



អំពើហិង្សាក្នុងគ្រួសារមួយបានកើតឡើង មានការវាយតប់ស្ត្រីជាប្រពន្ធ ព្រមទាំងជេរត្មះ តិះដៀលដល់ពូជអំបូរ ។



ស្ត្រីជាប្រពន្ធ បានចាកចេញពីផ្ទះខ្លួនឯង ទៅរស់នៅផ្ទះឪពុកម្តាយ សូម្បីឪពុកម្តាយអោយទៅរស់នៅជាមួយប្តី និងកូនវិញ ក៏ស្ត្រីនេះមិនព្រមដែរ ។

## ជំហរ




ក្នុងការដោះស្រាយទំនាស់ មិនអាចធ្វើទៅបានទេ ប្រសិនណា ភាគីទំនាស់ទាំងសង្ខាងប្រកាន់នូវជំហររៀងៗខ្លួនបែបនេះ ។ ដើម្បីដោះស្រាយទំនាស់បាន ភាគីទំនាស់ មិនត្រូវបញ្ឈប់ត្រឹមនេះទេ គឺត្រូវតែបន្តគិតដល់ចំណុច ផលប្រយោជន៍ និងតំរូវការ

## ផលប្រយោជន៍



ប្ដីប្រពន្ធដែលជាភាគីទំនាស់ ត្រូវគិតពីផលប្រយោជន៍រួមដូចជា គោ ក្របី សេះ ជ្រូក ផ្ទះសំបែង ស្រែ ក្ដី ឈ្មោះការរៀនសូត្ររបស់កូនៗ ...។ ប្រសិនបើភាគីទំនាស់គិតឃើញពីផលប្រយោជន៍នេះ អាចនាំទៅរក ដំណោះស្រាយបាន

## តំរូវការ



**តំរូវការរបស់ប្រពន្ធ :**

ប្រពន្ធចង់ឱ្យប្ដី ឈប់ផឹកស្រា ឈប់ដើរស្រវឹង អាឡេ អាឡូ ឈប់វាយប្រពន្ធ កូន មើលការរៀនសូត្ររបស់កូន រកលុយបានត្រូវឱ្យប្រពន្ធទុកដាក់ ខិតខំរកស៊ី ចិញ្ចឹមគ្រួសារ ជួយថែទាំគោ ក្របី ដាំដំណាំ ។



**គំរូចការរបស់ប្ដី :**

មិនចង់អោយប្រពន្ធដើរលេងផ្ទះគេ មិនចង់អោយនិយាយដើមគេ មិនចង់អោយនាំរឿងពីខាងក្រៅផ្ទះ ចូលមកក្នុងផ្ទះ ។ ម្យ៉ាងទៀតមិនចង់អោយដើរខ្ចី ចាន ឆ្នាំងគេមកប្រើទេ ។

**គំរូចការរបស់ប្ដី :**

ចង់ឱ្យប្រពន្ធ នៅផ្ទះ មើលការខុសត្រូវ ដាំស្ល ទាន់ពេលវេលាកូនទៅរៀន ។



# ជីវភាពគ្រួសារដែលគ្មានទំនាស់ និងគ្មានអំពើហិង្សាក្នុងគ្រួសារ



ក្រុមគ្រួសារ យល់ចិត្តគ្នាវិញ ហើយចាប់ដៃគ្នាកសាងសុភមង្គលដោយសន្យាថា ឈប់ប្រព្រឹត្តហិង្សា

**ការពិភាក្សា គឺជាមធ្យោបាយដ៏ប្រសើរបំផុតក្នុងការ ដោះស្រាយទំនាស់ក្នុងគ្រួសារ**

# ទំនាក់ទំនង

## ទំនាក់ទំនងល្អ



ទំនាក់ទំនងល្អ អាចធ្វើអោយយើងជៀសវាងពីទំនាស់ និងបង្កើតអោយមានភាពស្និទ្ធស្នាល និងជឿទុកចិត្តគ្នា។

## ទំនាក់ទំនងមិនល្អ



ទំនាក់ទំនងមិនល្អ បង្ហាញតាមរយៈកាយវិការដូចជា ជក់បារី អង្គុយគងអន្ទាក់ខ្លា បែរខ្នងដាក់ និយាយកាត់ និយាយងាកមុខចេញ និយាយចាកពីប្រធានបទ និយាយតែឯង...។

# របៀបខ្លះៗដែលធ្វើអោយមានទំនាក់ទំនងល្អ

- ប្រើវិធីសាស្ត្រច្រើនយ៉ាងដើម្បីបញ្ជាក់ពីព័ត៌មាន
- បង្កើនជំនាញស្ដាប់អោយបានល្អ
- ប្រើពាក្យសាមញ្ញស្រួលស្ដាប់
- ជ្រើសរើសពេលវេលាអោយសមស្រប
- ការយល់ចិត្តអ្នកដែលទទួលព័ត៌មាន

ប្រើព័ត៌មានត្រឹមត្រូវ ឬសាកសួរ

## ការនិយាយសំរាលបញ្ហា



# ការផ្ដល់ព័ត៌មានកែលំអ

ការផ្ដល់ព័តិមានកែលំអគឺជា ការផ្ដល់គំនិតស្ថាបនាទៅអ្នកដទៃ ដើម្បីអោយអ្នកនោះមានការរីកចំរើន

**ឧទាហរណ៍ ៖**



ក្មេងប្រុសម្នាក់កំពុងផ្ដល់ការលៃលំអទៅក្មេងប្រុសម្នាក់ទៀត ដោយលើកសរសើរ ហើយបាន រៀបរាប់ពីបញ្ហា ឥទ្ធិពលនៃបញ្ហា ព្រមទាំងផ្ដល់វិធីសាស្ត្រសំរាប់ធ្វើការកែលំអខ្លួន ។

**វិធីសាស្ត្រកែលំអអ្នកដទៃ**

⊗ លើកសរសើរសិន កែលំអអ្នកដទៃ

⊗ ប្រាប់ពីបញ្ហា ឬចំណុចខ្វះខាត

⊗ ប្រាប់ពី ផលប៉ះពាល់ នៃបញ្ហា

⊗ ប្រាប់ពី យុទ្ធសាស្ត្រ និងជំរើសផ្សេងៗ

# ការវិភាគទំនាស់

## ការវិភាគទំនាស់តាមដើមឈើ




ការវិភាគទំនាស់តាមដើមឈើគឺ វិភាគដើម្បីរកមូលហេតុ និងផលប៉ះពាល់នៃបញ្ហា ។ ហើយការវិភាគទំនាស់តាមដើមឈើនេះ ជាវិធីសាស្ត្រមួយសំរាប់ធ្វើការវិភាគជាក្រុម ជាស្ថាប័នអង្គការ ឬសហគមន៍ ដើម្បីកំណត់បញ្ហាដែលគ្រប់ៗគ្នាយល់ថា មានសារសំខាន់ ។ កាលណាយើងចង់ដឹងពីឬសគល់ និងឥទ្ធិពលមិនល្អនៃទំនាស់ យើងតោងតែ ធ្វើការវិភាគតាមវិធីសាស្ត្រដើមឈើនេះ ។ យើងប្រើសំណួរចំនួន ៣ សំរាប់សួរនៅពេលយើងធ្វើការវិភាគគឺ : ១-តើអ្វីជាបញ្ហាចំបង ? ២-តើទំនាស់នេះមានឬសគល់ ឬមូលហេតុអ្វីខ្លះ ? ៣-តើបញ្ហាសំខាន់ទាំងនេះបណ្តាលអោយកើតមានផលវិបាកអ្វីខ្លះ ? ។

# ការវិភាគទំនាស់តាមផែនទី

៣គន្លងនៅក្នុងផែនទីយើងអាចប្រើការសន្ទត់ ពិ-
សេសមួយដែលអ្នកអាចប្រឌិតដោយខ្លួនឯង ។



រង្វង់មូលនេះបង្ហាញអំពីភាគីនៅក្នុងស្ថានភាព
ទំនាក់ទំនងទំហំ=អំណាចដែលទាក់ទិនក្នុងបញ្ហា។



ខ្សែត្រង់បង្ហាញអំពីដំដែលតភ្ជាប់ នូវភាពទំនាក់
ទំនងជាអចិន្ត្រៃ មានរយៈពេលយូរមកហើយ ។



ខ្សែគូដែលតភ្ជាប់ បង្ហាញអំពីសម្ព័ន្ធមិត្ត



ខ្សែចុចៗ បង្ហាញអំពីទំនាក់ទំនងមិន
ផ្លូវការ មិនចានិច្ចកាល ឬមិនប្រក្រតី



ខ្សែសញ្ញាព្រួញ បង្ហាញអំពីទិសដៅសកម្ម
ភាព ឬ មានឥទ្ធិពលលើភាគីម្ខាងទៀត

## ការគូរផែនទីជាឧទាហរណ៍




ខាងលើនេះគឺជាឧទាហរណ៍ទ្រង់ទ្រាយផែនទីជំលោះ
ព្យាយាមធ្វើផែនទីជំលោះនៃស្ថានការណ៍ មួយ
ដែលអ្នកកំពុង

## សំណួរខ្លះៗដែលអ្នកត្រូវសួរមាន ៈ

- ⊗ អ្នកណាគឺជា ភាគីសំខាន់នៅក្នុងជំលោះនេះ ?
- ⊗ តើភាគីផ្សេងៗណាខ្លះដែលជាប់ពាក់ព័ន្ធនៅក្នុងនោះ រួមបញ្ចូលទាំងក្រុមដែលគេជិះជាន់ និងភាគីទៀតៗ ដែលនៅខាងក្រៅ?
- ⊗ តើមានទំនាក់ទំនងយ៉ាងណាខ្លះរវាងភាគីទាំងអស់ហើយ តើភាគីទាំងអស់នេះអាចជា តំណាងនៅក្នុង ផែនទីនេះយ៉ាងដូម្តេច? សម្ព័ន្ធមិត្ត?
- ⊗ តើមានបុគ្គលរវាងភាគីទាំងអស់ដែលត្រូវបង្ហាញក្នុងផែនទីនេះ?
- ⊗ តើមានបញ្ហាគន្លឹះអ្វីខ្លះ រវាងភាគីទាំងអស់ ដែលត្រូវបង្ហាញក្នុងផែនទីនេះ ?
- ⊗ តើខ្លួនអ្នកនិងអង្គការ/ស្ថាប័នរបស់អ្នកនៅកន្លែងណាក្នុង ទំនាក់ទំនងជាមួយភាគីទាំងអស់នោះ ?
- ⊗ តើអ្នកមានទំនាក់ទំនងពិសេសដែលអាចបើកចំហរ សំរាប់ ធ្វើការងារក្នុងស្ថានភាពជំលោះនេះទេ ?



ខ្សែរាងអង្កាញ់ៗដូចផ្លេកបន្ទោលបង្ហាញអំពីភាពមិនចុះសំរុង ឬមានជំលោះនឹងគ្នា



ខ្សែដែលមានគំនូសគូសកាត់ដូចជញ្ជាំង បង្ហាញអំពី ទំនាក់ទំនងមានការបែកបាក់ ឬត្រូវបានកាត់ផ្តាច់



សញ្ញាប្រអប់បួនជ្រុង /ទ្រវែងបង្ហាញអំពីបញ្ហាឬប្រធាននៃជំលោះ ហើយមិនមែនជាមនុស្សទេ។



ភាគីខាងក្រៅ

សញ្ញាស្រមោល ឬទារេកោង បង្ហាញអំពីភាគីខាងក្រៅដែលមានឥទ្ធិពលលើភាគីទំនាស់ ប៉ុន្តែមិនចូលរួមក្នុងជំលោះដោយផ្ទាល់ទេ ។

# វិធីសាស្ត្រ ដោះស្រាយទំនាស់

## ការដោះស្រាយទំនាស់តាមបែបចាញ់-ឈ្នះ



ការដោះស្រាយទំនាស់តាមបែប**ចាញ់-ឈ្នះ**គឺមានន័យថា ជាការដោះស្រាយដោយមានអ្នកទីពាងករាជ្យចូលរួម ដែលហៅថា" **អាជ្ញាកណ្តាល** "។អាជ្ញាកណ្តាលផ្តល់ដំណោះស្រាយបន្ទាប់ពីការសួរនាំពីភាគីទាំងពីររួច ហើយពិចារណាទៅលើអ្វី ដែល ត្រឹមត្រូវ និងមិនត្រឹមត្រូវ និងដោយផ្អែកលើផ្លូវច្បាប់ ។ អាជ្ញាកណ្តាលតែងតាំងជាផ្លូវការ និងលទ្ធផលការដោះស្រាយដោយផ្លូវច្បាប់ ហើយដំណើរការនេះធ្វើឡើងដោយមិនមានការស្ម័គ្រចិត្តទេ ។យើងឃើញថា លទ្ធផលចុងក្រោយនៃការដោះស្រាយទំនាស់គឺមានអ្នកសប្បាយ និងអ្នកកើតទុក្ខមានន័យថាភាគីម្ខាង " ចាញ់ " និងភាគីម្ខាងទៀត " ឈ្នះ " ។

## ការដោះស្រាយទំនាស់តាមបែបចាញ់-ចាញ់



ការដោះស្រាយទំនាស់តាមបែបចាញ់-ចាញ់ មានន័យថា គូភាគីទំនាស់ទទួលបានលទ្ធផលមួយដែលបរាជ័យទាំងអស់គ្នា ករណីដូចរឿងនិទានមួយដែលតំណាលអំពី សត្វភេទឹករាក់ និងភេទឹកជ្រៅដែលចាប់បានត្រីមួយ ហើយមិនចេះយោគយល់គ្នាក្នុងការបែងចែក ហើយក៏នាំគ្នាទៅពឹងពាក់សត្វចចកឱ្យជួយបែងចែក ទីបំផុតសត្វចចកនោះស៊ីស្ទើរត្រីអស់ ដែលសល់តែប៉ុនមេដៃពីរដុំ សំរាប់ភេនីមួយៗ ។

## ការដោះស្រាយទំនាស់តាមបែបឈ្នះ-ឈ្នះ

ការដោះស្រាយទំនាស់តាមបែបឈ្នះឈ្នះ គឺភាគីទំនាស់ទទួលបាន ជោគជ័យទាំងអស់គ្នា ដោយគ្មានអ្នកចាញ់ មានន័យថា ភាគីទំនាស់ ពិភាក្សាគ្នាយល់ព្រមទទួលជំរើសមួយ ដែលពួកគេ ពេញចិត្តដោយលក្ខណៈ យោគយល់ អធ្យាស្រ័យឱ្យគ្នា ។ចុងក្រោយនៃការដោះស្រាយទំនាស់ភាគីទំនាស់ ចាប់ផ្ដើមរាប់អានគ្នា ជាធម្មតាឡើងវិញ ។



# ដំណើរការដោះស្រាយបញ្ហា

## ការចរចារ




ការចរចារកើតឡើង រវាងគូភាគីទំនាស់ទាំងសង្ខាង ដើម្បីរកដំណោះស្រាយ រួមអោយមានការឯកភាពគ្នា

## វិធីចរចារតាមបែបឈ្នះ

- ⊗ បង្កើតវិន័យរួម
- ⊗ កុំវាយប្រហារលើបុគ្គល
- ⊗ ផ្តោតលើបញ្ហា
- ⊗ លើកយកផលប្រយោជន៍រួម និងតំរូវការ
- ⊗ បង្កើតជំរើសអោយបានច្រើន
- ⊗ ធ្វើកិច្ចសន្យានៅពេលមានការយល់ព្រម

# ការផ្សះផ្សា



⟹ ជាដំណើរការដោះស្រាយរវាងគូភាគីទំនាស់ សង្ខាងដោយមានភាគីឯករាជ្យ ផ្តល់យោបល់ ឬ រកដំណោះស្រាយ ។ ភាគីទីបី មិនអាចសំរេច ឬបង្ខំគេអោយយក ដំណោះស្រាយណាមួយឡើយ ។

⟹ **ដំណើរការនៃការផ្សះផ្សា :**

**១.ដំណាក់កាលរៀបចំ :** (ទីកន្លែងដែលមានបរិយាកាសល្អ កំណត់ពេលវេលា ត្រៀមសៀវភៅ ប៊ិចប្រឹតសំរាប់កត់ត្រា និងមាន ទឹកតែ កាហ្វេ នំ សំាប់ពេលចាប់ ផ្តើមការផ្សះផ្សា ។)

**២.ដំណាក់កាលចាប់ផ្តើម :** ( ធ្វើការស្វាគមន៍ បង្ហាញគោលបំណង និង តួនាទីអ្នកផ្សះផ្សា បង្កើតបទបញ្ជាផ្ទៃក្នុង រក្សាការសំងាត់ កត់ត្រាទុក ។)

**៣.ពេលមិនត្រូវរំខាន :** ( ឱ្យភាគីទាំងអស់យល់ព្រម ស្តាប់គ្នា-គ្រប់គ្នានឹង ប្រាប់ពីទស្សនៈរបស់ខ្លួនដោយគ្មានការរំខាន តែមិនត្រូវវាយប្រហារគ្នាទេ ។ឱ្យមានការ បង្ហាញពីអារម្មណ៍របស់ខ្លួនចំពោះស្ថានការណ៍ និងថាតើស្ថានការណ៍ នោះប៉ះពាល់ដល់ពួកគេក៏រិតណា ?)

**៤_ផ្លាស់ប្តូរយោបល់ ៖** (ភាគីទំនាស់សួរឆ្លើយគ្នាទៅវិញទៅមក តែត្រូវរក្សាការស្ងៀមស្ងាត់។ ប្រសិនបើអ្នកផ្សះផ្សាឃើញថាមានការតឹងតែងគួរបំបែកភាគីទំនាស់សិន ឬឱ្យសំរាកពិសារទឹកតែសិន។អ្នកផ្សះផ្សា យកល្អគួរតែ មានគ្នាពីរនាក់សំរាប់ជួយគ្នា ។)

**៥_បង្កើតកិច្ចសន្យា និងបិទការប្រជុំ ៖** (បង្ហាញភាគីទំនាស់នូវកិច្ចព្រមព្រៀងជាក់លាក់ ណាមួយ សំរាប់អនុវត្ត និងជួយក្នុងការសំរេចចិត្តលើកិច្ច ព្រមព្រៀងដែលត្រឹមត្រូវ ។ កិច្ចព្រមព្រៀងត្រូវសរសេរជាលាក់អក្សរ ហើយឱ្យភាគីទំនាស់ចុះហត្ថលេខា ។ ចុងក្រោយត្រូវថ្លែងអំណរគុណដល់ភាគីទំនាស់ ចំពោះកិច្ចសហការរបស់ពួកគេ ។)

⊗ **ការស្តាប់ជាជំនាញសំខាន់ ណាស់ក្នុងការដោះស្រាយបញ្ហា**

⊗ **សូមកុំមើលឃើញតែបញ្ហា សូមមើល_ ពីមូលហេតុរបស់វាផង ទើបធ្វើអោយយើងមាន ដំណោះស្រាយ ឈ្នះ_ឈ្នះ**

# សង្ខេបដំណើរការដោះស្រាយទំនាស់



១- ទំនាស់កើតឡើងហើយមានភាគីម្ខាងទៅពឹងពាក់អ្នកទីបី អោយជួយអន្តរាគមន៍

២- អ្នកទីបីសិក្សាពីទំនាស់នោះដោយសាកសួរ ពីឬគល់ និងបញ្ហា ដែលពាក់ព័ន្ធ អោយ បានច្បាស់

៣- ពិនិត្យលទ្ធភាពថាតើ អាចចូលដោះស្រាយបានដែរឬទេ?

៤- បើឃើញថាអាច អ្នកទីបីរៀបចំផែនការ ចុះទៅដោះស្រាយដោយឆ្លងតាមដំណាក់កាលដូចខាងក្រោមៈ

- វិភាគបញ្ហា ទំនាស់អោយបានច្បាស់លាស់ ដោយពិនិត្យ ទាំងមូលហេតុ ផលប៉ះពាល់ និងភាគីដែលពាក់ព័ន្ធទាំងឡាយ ។
- សិក្សាពីតំរូវការ ផលប្រយោជន៍ របស់ភាគីទំនាស់និមួយៗ
- រៀបចំពេលវេលា ទីកន្លែង សំរាប់ជួបជុំគ្នាដោះស្រាយទំនាស់នេះ
- បង្កើតវិនយ័សំរាប់ពេលដោះស្រាយ
- ក្នុងពេលដំណើការពិភាក្សា រកដំណោះស្រាយ អ្នកផ្សះផ្សារធ្វើយ៉ាងណា រក្សាអ-ព្យាក្រិតភាព និងរៀបចំបរិយាកាសកុំអោយមានបញ្ហា កើតឡើង ។ បើអាចធ្វើបាន គួជួយផ្តល់ជាគំនិត យោបល់ ឬដំណោះស្រាយដើម្បី អោយ ភាគីទំនាស់ សំរេច ជ្រើសរើសយក ។

## ⟹ សង្ខេបចំណាំ

- អ្នកផ្សះផ្សា មិនសំរេច ជ្រើសរើសយកដំណោះស្រាយដែលខ្លួនផ្តល់ អោយ ឡើយ ឬបង្ខំអោយគេទទួលយកឡើយ ។ ដំណោះស្រាយដែលសមស្រប គឺជាដំណោះស្រាយ ដែលភាគីទាំងសងខាងពេញចិត្តទទួលយក-ករៀងៗខ្លួនដោយមិនបង្ខំហើយឆ្លើយតប ទៅនិងតំរូវការ និងផលប្រយោជន៍ របស់ខ្លួន ។
- ពេលភាគីទាំងពីរយល់ព្រមលើដំណោះស្រាយហើយអ្នកផ្សះផ្សា ត្រូវជួយ សំរបសំរួល ធ្វើកិច្ច សន្យា។ កិច្ចសន្យាត្រូវតែបញ្ជាក់អោយច្បាស់ ពីបញ្ហា ដែលត្រូវដោះស្រាយ និងផែនការ សកម្មភាពពេលអនាគត។

## កម្មវិធីរបស់អង្គការសីលការ ៖

### អង្គការសីលការមានកម្មវិធីដូចតទៅ ៖

បង្កើនសមត្ថភាពជាការត្រួសត្រាយផ្លូវសំរាប់អនាគត!

**សីលការមានសេវា៖**

ការពិគ្រោះយោបល់

ការកសាងសាមគ្គីភាព

ការដោះស្រាយទំនាស់ និងការ

ស្រាវជ្រាវការអភិវឌ្ឍន៍ ។ល។

**សីលការមានវគ្គអ្វីខ្លះ?**

- គ្រូបង្គោល
- ដឹកនាំ គ្រប់គ្រង
- គ្រប់គ្រងហិរញ្ញវត្ថុ
- សរសេរគំរោងសំណើ
- សរសេររបាយការណ៍
- ធ្វើផែនការ
- ទំនាក់ទំនង
- ត្រួតពិនិត្យ និង វាយតំលៃ
- ដោះស្រាយទំនាស់
- ជំនាញកិច្ចការ ការិយាល័យ
- ម៉ាឃីធីង................

**និងវគ្គជាច្រើនទៀត ទៅ**
**តាមសេចក្តីត្រូវការរបស់លោកអ្នក ។ល។**

### សូមលោក-អ្នកស្វែងរកការបង្កើនសមត្ថភាពជាមួយ

# អង្គការសីលការ !


**អាសយដ្ឋាន** ៖

ប្រអប់សំបុត្រ លេខ ៨២១

ផ្ទះលេខ 6 S ផ្លូវលេខ 21 សង្កាត់ទន្លេបាសាក់

ខណ្ឌចំការមន ក្រុងភ្នំពេញ

ទូរស័ព្ទលេខ : 023 217 872

E-mail : silaka@silaka.org

Fax : (855) 23 213 108

# សីលការ

## ទស្សនវិស័យ

អង្គការសីលាការមានទស្សនវិស័យដូចតទៅ :

- សង្គមកម្ពុជាផ្តោតទៅលើការរៀនសូត្រជាចំហ និងការអភិវឌ្ឍន៏ធនធានមនុស្ស ដើម្បីធ្វើអោយកាន់តែប្រសើរឡើងនូវស្នាដៃ អង្គការ និង ស្ថាប័នខ្លួន ។
- អង្គការ និងស្ថាប័នកម្ពុជាក្នុងការធ្វើការងារ ដើម្បីបំរើ និង ការពារផលប្រយោជន៏រួមរបស់ប្រជាជនកម្ពុជា ដោយមិនរើសអើងពីយេនឌ័រ អាយុ ពូជសាសន៏ សាសនា ជនជាតិភាគតិច និងពិការភាព ។
- ប្រជាជនកម្ពុជាប្រឹងប្រែងរួមគ្នាដើម្បីនាំមកនូវការផ្លាស់ប្តូរសង្គមជាវិជ្ជមាន ដែលលើកតម្កើងការអភិវឌ្ឍន៏ ដែលមាននិរន្តភាព និងធ្វើកាន់តែប្រសើរឡើង នូវជីវភាពប្រជាជន។
- ប្រជាជនកម្ពុជាប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីសង្គមមួយដែលឈរលើការគោរពសិទ្ធិមនុស្ស ដើម្បីលើតម្កើង ប្រជាធិតេយ្យ និងការផ្សះផ្សាដើម្បីសន្តិភាព និងសុភមង្គលនៅក្នុងប្រទេសកម្ពុជា ក្នុងតំបន់ និង ក្នុងពិភពលោក ។

## បេសកកម្ម

- ជួយអប់រំ និងរៀបចំប្រជាជនកម្ពុជាដើម្បី បង្កើត អភិវឌ្ឍ និងពង្រឹងអង្គការ និងស្ថាប័ន
- ធ្វើការជាមួយបុគ្គល អង្គការនិងស្ថាប័ន ដែលទាក់ទិនយ៉ាងខ្លាំង ជាមួយការកសាង សមត្ថភាព ដល់ប្រជាជនកម្ពុជា
- ចូលរួមចំណែកក្នុងការកសាងសន្តិភាពនៅកម្ពុជា ដោះស្រាយទំនាស់ដោយស្ថាបនា និងការដោះស្រាយ បញ្ហាអោយមានប្រសិទ្ធភាព ។

## កម្មវិធី

អង្គការសីលការមានកម្មវិធីដូចតទៅ :

- ការពិគ្រោះយោបល់
- ការកសាងសាមគ្គីភាព
- វគ្គហ្វឹកហ្វឺន
- ការដោះស្រាយទំនាស់ និង ការស្រាវជ្រាវ/ការអភិវឌ្ឍន៏ ។

# មេត្តាធម៌_កម្មវិធីកែប្រែទំនាស់

## គោលបំណង និងគោលដៅ

**មេត្តាធម៌_កម្មវិធីកែប្រែទំនាស់** (Metathor-CTP) របស់អង្គការសីលការ ត្រូវបានបង្កើតឡើង ដើម្បីចូលរួមចំណែកក្នុងការកសាងសន្តិភាពនៅកម្ពុជា ការដោះស្រាយទំនាស់ក្នុងន័យស្ថាបនា និងការដោះស្រាយទំនាស់មានប្រសិទ្ធភាពតាមរយៈការកសាងសមត្ថភាព ការបណ្តុះបណ្តាល ការគាំទ្របណ្តាញ និង សេវាពិគ្រោះយោបល់ ។ ដើម្បីសំរេចបាននូវគោលបំណងនេះ អ្នកចូលរួមទាំងឡាយ ត្រូវបានអញ្ជើញអោយចូលសិក្សាដោយរួមសហការជាមួយដៃគូគំរោងដែលពាក់ព័ន្ធ ដើម្បីសិក្សាអំពីតួនាទីទំនាស់ ផលប៉ះពាល់នៃទំនាស់ទៅលើសង្គម និងវិធីសាស្ត្រដែលអាចកែប្រែទំនាស់អោយឈានទៅរកការអភិវឌ្ឍន៍ និង ការរីកចំរើន ។

## ប្រវត្តិ

សង្គ្រាមស៊ីវិលជាច្រើនទសវត្សរ៍ បានបំផ្លាញការចេះដឹងរបស់មនុស្សក្នុងការដោះស្រាយ ទំនាស់ជាមួយគ្នា ដោយសន្តិវិធីទាំងសីលធម៌របស់ប្រជាជន និងយន្តការសង្គម ក្នុងការគ្រប់គ្រងទំនាស់ផងដែរ ។ ចាប់តាំងពីឆ្នាំ១៩៩៧ សីលការជាអង្គការមួយដែលធ្វើការលើផ្នែកបង្កើនសមត្ថភាព និងការបណ្តុះបណ្តាលនៅក្នុងប្រទេសកម្ពុជា ។ ការបង្កើតនូវមេត្តាធម៌-កម្មវិធីកែប្រែទំនាស់ និងការកសាងសន្តិភាពក្នុងអង្គការ សីលការនៅខែវិច្ឆិកា ២០០១ ផ្តើមចេញពីបទពិសោធន៍លើការដោះស្រាយទំនាស់ ហិង្សា និងវិបត្តិនយោបាយ នៅក្នុងឆ្នាំ ១៩៩៧-១៩៩៨ ជាពិសេសការចូលរួមចលនាធម្មយាត្រា នៅក្នុងយុទ្ធនាការបោះឆ្នោតឆ្នាំ ១៩៩៨ ដោយបានសហប្រតិបត្តិការជាមួយ បណ្តាអង្គការសង្គមស៊ីវិលចំនួន ៧០ អង្គការ ។ កម្មវិធីនេះទទួលបានការឧបត្ថម្ភគាំទ្រពីសេវាអភិវឌ្ឍន៍ អាឡឺម៉ង់ (DED) ក្រោមកម្មវិធីទប់ស្កាត់វិបត្តិកែប្រែទំនាស់ និងការកសាងសន្តិភាពរបស់អាឡឺម៉ង់ ( Gernab ZFD Program) ។

## សកម្មភាព

**មេត្តាធម៌_កម្មវិធីកែប្រែទំនាស់** ផ្តល់នូវការបណ្តុះបណ្តាលលើផ្នែក

- ការវិភាគទំនាស់
- ជំនាញទំនាក់ទំនង
- យុទ្ធសាស្ត្រដោះស្រាយទំនាស់ (ដូចជាការចរចារ ការផ្សះផ្សា និង ការសំរបសំរួល)
- អហិង្សាសកម្ម និងការតស៊ូមតិ
- ច្បាប់ដែលទាក់ទង (ដូចជា ដីធ្លី ព្រៃឈើ ជលផល)
- ប្រពន្ធ័វិមជ្ឈការ

ក្រៅពីវគ្គបណ្តុះបណ្តាលខាងលើ មេត្តាធម៌-កម្មវិធីកែប្រែទំនាស់ ក៏ផ្តល់ជូនបន្ថែមផងដែរនូវៈ

- ការគាំទ្រក្នុងការតាមដានចំពោះសិក្ខាកាមដែលបានចូលរួមក្នុងការបណ្តុះបណ្តាល ។

- ការគាំទ្របណ្តាញដល់អង្គការ និងស្ថាប័នអង្គ និងស្ថាប័ននានានៅក្នុងការដោះស្រាយទំនាស់ និងការកសាងសន្តិភាព

ក្រុមគោលដៅ

**មេត្តាធម៌_កម្មវិធីកែប្រែទំនាស់** ផ្តល់ការបណ្តុះបណ្តាលដល់អ្នកចូលសិក្សាមកពីបណ្តាគ្រប់អង្គការ និងស្ថាប័នផ្សេងៗ ដែល មានសកម្មភាពពាក់ព័ន្ធទៅនឹងការដោះស្រាយទំនាស់ និងការកសាងសន្តិភាពដូចជា :

- អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិ
- ស្ថាប័នរដ្ឋាភិបាលថ្នាក់ខេត្ត
- ក្រុមប្រឹក្សាឃុំសង្កាត់
- មន្ត្រីថ្នាក់ស្រុក
- គណៈកម្មការវត្តអារាម
- មេភូមិ